១៩៤-ផាឌិបផាម្ទួងពណ៌ទទឹម    សង្កិមសង្កៀនខៀនកម្ចី
មាសដាក់សក្លាតព្រែលាតថ្មី    ព្រែសូត្រជាតិទេសឯកផ្កា ។
១៩៥-ចានជើងចានស្តើងចានសម្ល    ចានថ្មចានទាបបារាំងលាយ
រៀបដាក់ផ្សារកាំបិតប្រណាក    កាំបិតព្រាចែតផ្គាក់កាប់ព្រៃ ។
១៩៦-ឯកដើរទាំងពីរទៅឯជើង    ដើរឡើងទៅដល់ពាមផ្លូនៃ
ឃើញឈ្មួញលក់ដូរទិញទ្រព្យថ្លៃ    ច្រើនក្រៃចង្អៀតប្រជៀតគ្នា ។
១៩៧-អ្នកខ្លះយកកាសដូរជាប្រាក់    ដើរដូរប្រទាក់ឈ្លោះគ្នាឆោ
ជេរម្តាយប្រវាប្រធាក់គ្នា    ស្រីៗរើវានផ្សារជ្រកទៀមចិន ។
១៩៨-អ្នកខ្លះស្រវឹងលាត់ក្អេងក្អាង    ឃុំភ្លាមស្ទុះផាងធ្វើជាប៉ិន
លោទាត់វាភ្លាត់របូតក្បិន    ចិនស្ទុះមកដាល់ដួលចង្ក្រាង ។
១៩៩-ឯអស់ស្រីផ្សារយល់អ្នកឯក    រូបល្អចម្លែកឈរហឹងហាង
គាស់គ្នាថារើយមើលវាង    ប្រុសយ៉ាងនេះមកពីស្រុកណា ។
២០០-ខ្លះហៅថានែអ្នកកំលោះ    ឈរនោះមកនេះពីសាស្លា
ទិញអ្វីអញ្ជើញមកអាយវ៉ា    ខ្លះស្រែកហៅថាមកឯនេះ ។
២០១-បើចង់ទិញអ្វីខ្ញុំមានគ្រប់    បារីសឹងអប់ប្រេងក្រចេះ
ដន្លាប់សឹងអប់ផ្កាម្លិះ    ស្រីខ្លះឈរវិះមើលសើចម្តងៗ ។
២០២-នាងខ្លះបើកស្បៃចេញពីក    ចុងដោះសៗល្អបំព្រង
ចង់ឱ្យអ្នកឯកចាប់ស្នេហ៍ស្នង    ធ្វើឫក្សទំនងជាសង្សារ ។
២០៣-ស្រីខ្លះអង្គុយជិតខាងប្តី    ស្មានអ្នកដទៃគេទិញស្លា
ភ្លេចកូនភ្លេចចៅវារចូលផ្សារ    ពុំបាននឹកនាវារកកូន ។
២០៤-ស្រីខ្លះរើសរកម្លូសំរង    បៀកផ្ទង់នឹងប៉ងយកទៅជូន
ខ្លះធ្វើជាស្និទ្ធហាក់បងប្អូន    ពុំដឹងកេរខ្លួនជាខ្មាស់គេ ។
២០៥-តាក់តែងតែខ្លួនឱ្យស្អាងស្អាត    រឺឯមារយាទដូចកាកី
កាលណាបើឃើញប្រុសដទៃ    ចិត្រចង់មេត្រីផិតប្តីដើម ។
២០៦-ចៅឯកមៀងមើលឃើញស្រីៗ    ធ្វើរឹងមេត្រីមកពព្រឹម
ពព្រើតពព្រាកញាក់ចិញ្ចើម    មកឱ្យឯកស្មើមឈរប្រងើយ ។

២០៧-គិតតែនាងទាវពុំមានភ្លេច
ឃើញស្រីផ្សារហៅពុំមានឆ្លើយ
បែរទៅហៅពេជ្រធ្វើកន្តើយ
ស្រេចហើយចរចុះទៅនារា ។

២០៨-ដល់ទូកចេញស្រូតទាំងយប់ថ្ងៃ
នាំចូលទៅដល់ព្រះរាជា
បានដល់ហើយនៃឡើងម្ទីម្នា
រាមាធិរាជក្សត្រឥសូរ ។

២០៩-អាជ្ញាលើកករឱនសិរថ្វាត់
ថាយើងនេះសូមក្រាបពិតទូល
បង្គំមហាក្សត្រជាកំពូល
ពុំចេរតែទ្រង់មេត្តាប្រោស ។

២១០-ដ្បិតទ្រង់ត្រាស់ប្រើអស់អាជ្ញា
ទៅរកអ្នកច្រៀងឱ្យលេចលើស
អញ្ជើញឱង្ការចេញទៅរើស
ទូលបង្គន់ដើររើសបានពីរនាក់ ។

២១១-មួយឈ្មោះចៅឯកប្លែកឮលេច
ទាំងច្រៀងផ្លុំប៉ីពុំមានអាក់
មួយឈ្មោះចៅពេជ្រសមសួនសក្តិ
ពីរនាក់បានមកពីត្បូងឃ្មុំ ។

២១២-ស្តេចស្រួលហើយមានបន្ទូលថា
ពេជ្រយកប៉ីមកលើកឡើងផ្លុំ
ចៅឯកឯងច្រៀងបទខ្នងភ្នំ
ចៅឯកច្រៀងផ្សំសូរស្រងាត់ ។

២១៣-ភិរម្យសមគ្នាដូចគេបិទ
ដំណើរទំនងពីរោះក្តាត់
គ្រលួចក្នុងចិត្រត្រូវគ្នាមាត់
ចេះស្ទាត់ទាំងច្រៀងទាំងផ្លុំប៉ី ។

២១៤-ច្រៀងថាស្រណោះខ្យល់រំភើយ
ឥឡូវអម្ចាស់លើសិរីសី
បក់មករហើយផ្អូកប្អូនស្រី
ទ្រង់ប្រោសប្រណីយកបងបាន ។

២១៥-ម្ល៉េះសមប្អូនមាសមិត្រស្នេហា
ចាំបែងចាំបក់ស្ទាត់ទីឋាន
ជាទុក្ខខ្លោចផ្សាពុំស្រាកស្រាន្ត
ធ្វើម្តេចឱ្យបានយល់មុខគ្នា ។

២១៦-ស្តេចឮឯកច្រៀងពីរោះក្តាត់
ស្រីទិព្វនេត្រៗ ទិព្វជា
មានបន្ទូលថ្វាត់នឹងឧកញ៉ា
តាំងឯកឱ្យជាម៉ឺនភិរម្យ ។

២១៧-សម្រួចខាងច្រៀងជាសម្រេច
ប្រទានយសសក្តិឱ្យជាធំ
ចៅពេជ្រឱ្យជាម៉ឺនឧត្តម
បើកទាំងបៀរត្សរ៍ឱ្យរាល់ខែ ។

២១៨-ឯអស់ខុនណាងនាងអ្នកក្នុង
ស័ព្ទសូរឯកច្រៀងសៀងល្វើយល្វេរ
យល់អង្គអ្នកឯកប្លែកជាងគេ
សឹងតែស្រឡាញ់ពេញស្នេហា ។

២១៩-រួចស្រេចស្តេចចូលព្រះបន្ទំ
ត្រឡប់វិលមកឋានគ្រឹហា
ឯកថ្វាយបង្គំសូមក្រាបលា
ឡើងគាល់ក្សត្រាជាប្រក្រតី ។

២២០-ឬឯបណ្ដាអ្នកក្នុងវាំង    អស់ទាំងនាម៉ឺនមុខមន្ត្រី
ស្រឡាញ់ឯកពេជ្រច្រៀងផ្លុំប៉ី    ឮល្បីកេរ្តិ៍ឈ្មោះព្រោះក្សត្រា ។
២២១-កាលនោះឯអង្គព្រះមហាក្សត្រ    មានបន្ទូលថ្វាត់នឹងឧកញ៉ា
ចាងហ្វាងជ័យឆាប់ប្រញាប់ការ    ឱ្យតែងឱង្ការចេញទៅកែន ។
២២២-ទៅរកព្រះម្នាងស្រុកក្រៅ    មានរូបល្អេញល្អៅល្អមែនទែន
រើសរកអាជ្ញាឱ្យរៃកែ្ងន    អាជ្ញាផងកែនគ្នាចេញទៅ ។
២២៣-ដើររកគ្រប់ខែត្រគ្រប់ភូមិឋាន    ទើបបានឃើញទារល្អស្រងៅ
ឃើញទាំងទ្រង់ទ្រាយឆើតឆោមឆ្លៅ    មើលទៅហាក់ដូចព្រះចន្ទ្រា ។
២២៤-គន់សក់ៗសោតខ្មៅដុកជិត    រង់ភ្នែកដូចកូនម្រឹគា
ថ្ពាល់ពេញប៉ផ្ទូរផង់ផាត់ណា    ,    រិមមាត់ដិតស្លាស្រស់ប៉ប្រៃ ។
២២៥-ល្អគ្រប់មិនមានទាស់ត្រង់ណា    អាជ្ញានាំរនាំមកឆាប់ក្រៃ
ឡើងជូនឧកញ៉ាវាំងវៀងជ័យ    ពួកស្រីជំទាវនាំចូលថ្វាយ ។
២២៦-ព្រះបាទរាមាជាចមក្សត្រ    យល់រូបស្រីរ័ត្នឆើតឆោមឆាយ
មានព្រះអំណរអររីករាយ    ទារថ្វាយបង្គំក្រួញក្រាបនៅ ។
២២៧-លុះថ្ងៃរសៀលទន់ត្រជាក់    ម៉ឺនឯកម៉ឺនពេជ្រនាំគ្នាទៅ
ច្រៀងថ្វាយសម្ដេចព្រះចមចៅ    ក្រឡេកមើលទៅឃើញទារជាក់ ។
២២៨-រន្ធត់ស្លុតស្លាំងគាំងស្មារតី    ហេតុម្ដេចស្រីថ្លៃមាសរលក្ខណ
ចូលមកនៅក្នុងព្រះដំណាក់    រីស្រីនាងស្ម័គ្រមកតាមបង ។
២២៩-នាងទារមៀងមើលឃើញម៉ឺនឯក    ក្នុងទ្រូងស្ទើរបែកភក្ត្រសៅហ្មង
ពុំហ៊ានសាកសួរអស់អ្នកផង    ក្រែងកើតឆ្គាំឆ្គងដល់អាត្មា ។
២៣០-ម៉ឺនឯកស្រែកច្រៀងទៀងទូលទៅ    សូមទានព្រះចៅទ្រង់មេត្តា
សម្លាប់ទាល់ស្លាប់ទុកគង់ជា    ខ្ញុំព្រះបាទាតទៅមុខ ។
២៣១-ដ្បិតនាងទារនេះជាសង្សារ    ខ្ញុំព្រះករុណានៅឯស្រុក
ឥឡូវនេះស្រាប់តែឃើញមុខ    យាងមានអ្នកស្រុកនាំមកថ្វាយ ។
២៣២-ស្ដេចស្ដាប់ឯកច្រៀងហើយសូមទោស-ទ្រង់បន្ទូលថានែទារអើយ
ម៉ឺនឯកថាឯងជាសហាយ    របស់គេនៅនាយមែនឬទេ

២៣៣- នាងទារលើកករថ្វាយបង្គំ ទាំងទាល់ថាខ្ញុំម្ចាស់តាមតែ
ព្រះទ័យប្រោសប្រាណឱ្យគង់គេរ សហាយមែនតែយូរហើយណា ។
២៣៤- នាងទារនឹងទូល (ស្ដេច) ឱ្យអស់ ខ្លាចស្ដេចពុំប្រោសយកទោសា
បញ្ចៀងបន្តិចឱ្យជ្រាបការ បើទ្រង់មេត្តាសឹមស្នើទៀត ។
២៣៥- ស្ដេចទ្រង់ព្រះស្រួលបន្ទូលរៃ ចិត្រអញនេះនៃពុំជ្រៀតបៀត
ឱ្យឯកនឹងទារយកគ្នាទៀត អញរៀបឱ្យឯកថ្វាយបង្គំ ។
២៣៦- អញមើលរូបរាងនាងទារនេះ ល្អអុយល្អម៉្លេះគួរសក្ដិសម
គិតនឹងលើកឡើងឱ្យជាធំ យុនចក្ខុបទុមសម្រាប់ត្រី ។
២៣៧- ឥឡូវទារជាសង្សារឯក ហើយចុះអញលែងបេតី
ស្មារលាកុំឱ្យមានទោសភ័យ ពីជាតិនេះក្ដីតទៅមុខ ។
២៣៨- ម៉ឺនឯកម៉ឺនពេជ្រនឹងទារណា នៅជាមួយគ្នាបានសាន្តសុខ
មានខ្ញុំកំដរប្រើស្រណុក ឥតទុក្ខដល់ពេលឡើងច្រៀងថ្វាយ ។
២៣៩- ថ្លៃងឯនាងទារជាភរិយា ថ្ងៃនោះជាកាលពុំសប្បាយ
ភ្នកនឹករព្ញកទៅដល់ម្ដាយ ក្នុងទ្រូងស្ទើរធ្លាយសោកសៅហ្មង ។
២៤០- ម៉ឺនឯកយល់នាងទារអផ្សុក ដឹងជាកើតទុក្ខបីត្រកង
ថើបហើយអង្អែលសួរទំនង ហេតុម្ដេចប្អូនបងមិនសប្បាយ ។
២៤១- នាងទារឃើញប្ដីថ្នមស្នេហា ប្រាប់ថាខ្ញុំនឹករព្ញកម្ដាយ
ម៉្លេះគាត់ពីបាកនៅឯនាយ អត់ឃ្លានក្រងាយគ្មាននរណា ។
២៤២- សូមអ្នកអាណិតបើកប្អូនទៅ យូរណាស់ដេកផ្លូវប្រាំទិវា
ឱ្យឃើញមុខម្ដាយម្ដងទៅរ៉ា ម៉្លេះគាត់ជរាចាស់ម្ដេចទៅ ។
២៤៣- ម៉ឺនឯកលោមហើយអង្វរថា ប្អូនស្ងួនសង្សារកុំសោកសៅ
បើប្អូនរព្ញកម្ដាយសឹមប្រើបាវ ឱ្យទៅសួរគាត់ក៏បានដែរ ។
២៤៤- នាងចង់ទៅថ្វីឱ្យព្រួយប្រាណ ស្រុកឆ្ងាយហើយមានឆ្លងទន្លេ
ក្រពើឆ្លាមមករហែលលលេ រាឃើញទូកគេដេញត្របាក់ ។
២៤៥- ប្អូនអើយបងគិតថប់ច្រើនយ៉ាង ឯចិត្រម្ដាយនាងគាត់ស្មោះស្ម័គ្រ
ស្រឡាញ់អាង្គនរាមានប្រាក់ ចិត្រប្អូនរលក្នុណ៍ក៏ស្ម័គ្រផង ។

២៨៦-ប្អូនកុំទៅពៅពន្លក　បារមកគង់តែរាប្រាប់បង
ហើយដឹងដំណឹងដោយទំនង　កុំប្អូនទង្វងនាងព្រួយប្រាណ ។
២៨៧-នាងទាវបានឮពាក្យប្ដីឃាត់　រន្ធត់ស្លុតចិត្តរិតរំខាន
ហេតុតែកម្មនាងនឹងឱ្យមាន　ទុក្ខទោសដល់ប្រាណស្លាប់អាត្មា ។
២៨៨-ប្រះប្រាណលើខ្នើយហើយសោកសៅ　វិយោគទួញយំក្រំឈឺផ្សា
បាយទឹកពុំនឹកនឹងភោក្តា　ស្គាំងស្គមអាត្មាធ្វេសវិញ្ញាណ ។
២៨៩-ម៉ឺនឯកឃើញទាវដូច្នេះ　ពីគ្រោះទៅឃើញឃាត់ពុំបាន
បែរទៅត្រកងប្អូនកល្យាណ　បើកហើយនាងបានក្សាន្តទុក្ខា ។
២៩០-នាងទាវឡើងគាល់ព្រះមហាក្សត្រ　ក្រាបទូលដោយចិត្តចង់ក្រាបលា
ទៅខែត្រត្បូងឃ្មុំសួរមាតា　សូមទ្រង់ករុណាប្រោសប្រណី ។
២៩១-ស្ដេចបើកហើយទ្រង់ផ្ដាំថា　ឯកទាវម្ដេចម្ដាឆាប់វិលរិះ
កុំនៅបង្អង់ឱ្យយូរថ្ងៃ　នាងទាវអរក្រៃបង្គំលា ។
២៩២-មកដល់ផ្ទះហើយនាងទាវប្រាប់　បាវឱ្យប្រញាប់រៀបទូកក្ដារ
អង្ករប្រហុកត្រីងៀតប្រា　ដាក់ទៅបង្ការស៊ីតាមផ្លូវ ។
២៩៣-រៀបស្រេចនាងទាវចរចុះទូក　ចិន្ដាផ្អើលផ្អកសោកហ្មងសៅ
ព្រោះខ្លួនបែរបែកពីឯកទៅ　សែនក្ដៅក្នុងម្នោទោមនស្សា ។
២៩៤-ចេញឆ្លងកាត់ទៅចុងកោះចិន　ដើងថែរសឹងបិនប្រណាំងគ្នា
នាងនឹកដល់ឯកជាសង្សារ　ឱរាស្ទើរបែកសញ្ញែកចេញ ។
២៩៥-មើលកោះកោងកៀនជ្រៅសន្លឹម　មេឃមីរទូទឹមរឹងម្នោម្នេញ
ឃើញអស់ចាមជ្វាពាក់មងពេញ　នាមអួនសំណាញ់ម៉ាញ់ថៃវ៉ា ។
២៩៦-មកដល់ដូនស្ដើងពាក់ព្រ័ត្រហើយ　ជំនោររំភើយរែងរងា
ឯត្រើយខាងលិចលេចភូមិពញា　ឮលោកតែងថាស្វាសូមទាន ។
២៩៧-មកដល់ភូមិត្រស់ឃើញព្រែកព្នៅ　មើលទៅផ្សារចិនដាក់រាល់រាន
លក់ដូរទំនិញអ្វីសឹងមាន　ជជែកគ្នាសាន្តទូកត្រៀបត្រា ។
២៩៨-ឯត្រើយខាងកើតព្រែកត្រសេក　ក្រឡេកមើលទៅផ្ទះលាំងការ
ឯត្រើយខាងលិចសុទ្ធតែជ្វា　ភូមិនោះគេថាច្រាំងចម្រេះ ។

២៥៩-ខំប្រឹងថែរកាត់ដល់ឫស្សីកែរ    អ្នកថែរត្អូញថាវាអោយចង្កេះ
នាងឃើញភ្នំពេញទ្រូងស្មើរប្រេះ    ប្រើឱ្យវាតរេះចូលលេងផ្សារ ។

២៦០-ចូលមកស្រេចហើយហៅមេនោ    ហងបើកហិបយកប្រាក់មកវ៉ា
អញឡើងទៅមើលទិញទ្រព្យា    ទេសឯកទេសផ្កាទៅផ្ញើម្ដាយ ។

២៦១-ឯអស់កំលោះអ្នកលេងផ្សារ    យល់ឫកឆាយាទាវឆើតឆាយ
រជោររដើបស្រើបរាល់កាយ    តាមមើលពីឆ្ងាយកើតស្នេហា ។

២៦២-អ្នកខ្លះសួរគ្នាថានាងនេះ    ល្អម្ល៉េះតើមកពីស្រុកណា
ជាស្រីអ្នកស្រែឫថំការ    បើម្ល៉េះទៅវ៉ាល្អមស៊ូស្លាប់ ។

២៦៣-ប្រសិននាងនេះបានមកអញ    ទោះក្រម្ដេចមិញនឹងរងវ៉ាប់
តាំងទុកក្នុងផ្ទះឱ្យស៊ីស្រាប់    ធានានឹងផ្គាប់ឱ្យដល់យ៉ាង ។

២៦៤-ខ្លះធ្វើជាស្និទ្ធឈរជិតទាវ    សួរទៅថានែអ្នកមានរាង
នាងទាវគេសួរធ្វើហេងហាង    ស្គាល់យ៉ាងគេចង់មិនស្បិតស្ដី ។

២៦៥-អ្នកខ្លះប្រឹងមើលស្រឡាំងកាំង    ភ្លេចភ្លាំងរន្ធត់ស្លុតស្មារតី
ខ្លះប្លែកឈរវែកនៅរានត្រី    ហាលថ្ងៃបែកញើសមិនដឹងខ្លួន ។

២៦៦-នាងទាវទិញខៀនប្រាំកាឡី    ព្រៃលាំងទាំងកីសំពត់ទួននៃយកទៅផង[232]
គ្រាន់និងចែកឱ្យអស់បងប្អូន    ទេសឯកនឹងជូនជាបញ្ញើ ។

២៦៧-រួចហើយនាងចរចុះចេញទូក    អ្នកផ្សារតាមភ្លូកមើលពីលើ
ចេញទូកថែរលឿនលើសសត្វហើរ    កាត់ឆ្លងទៅលើជ្រួយចង្វា ។

២៦៨-ក្រឡេកមើលឃើញកោះខ្សាច់    កណ្ដាលបន្តិចលេចកោះស្នា
ដល់ភូមិកៀនឃ្លាំងឈប់ស៊ីស្លា    ពុំបានពណ៌នារាវរាប់កោះ ។

២៦៩-កាលម៉ឺនឯកមករាប់រួចហើយ    ពុំមានសល់ឡើយដោយចន្លោះ
រាប់ស្រុករាប់ភូមិតាមដោយកោះ    បណ្ដោយចុះមកបានដល់អាយ ។

២៧០-នាងទាវឱ្យស្រូតទាំងថ្ងៃយប់    មិនឱ្យឈរឈប់រឮកម្ដាយ
មកដល់កំពង់ឡើងប្រញាប់    ប្រើឱ្យដាំបាយស៊ីរាល់គ្នា ។

២៧១-នាងទាវឡើងទៅឃើញមុខម្ដាយ    ត្រេកអររីករាយអស់ទុក្ខា

[232] Ce vers a quatre syllabes de trop.

បងប្អូនជិតឆ្ងាយមករាល់គ្នា    ដោយសារនាងមកពីស្រុកឆ្ងាយ ។
២៧២-នាងយកខ្មៀនមកស្រាយចែកជូន    ដោយបងដោយប្អូនពុំគិតស្តាយ
អ្នកខ្លះទៅរកដណ្តាំបាយ    ស្ងោរមាន់សែនថ្វាយអស់ចាស់ទុំ ។
២៧៣-នាងនៅយូរទៅសុខសប្បាយ    ឬឯម្តាយទារគិតសុខដុម
ទៅប្រាប់អរជូនឱ្យរៀបចំ    លើកផ្កាស្លាធំស្រេចតែម្តង ។
២៧៤-ក្សិណនោះឯនាងទារបានដឹង    ដោយនូវដំណឹងការទំនង
នាងគិតបារម្ភពេកកន្លង    ញាប់ញ័រអស់អង្គស្មើរមរណា ។
២៧៥-នាងហែកចេសមកផ្គួផ្គង    គិតតែម្នាក់ឯងក្នុងប្រាជ្ញា
មិនឱ្យអ្នកផងគេដឹងការ    ធ្វើជាអក្ខរាដាក់ក្នុងថង់ ។
២៧៦-សម្នាតែងជាសំនួរមក    ប្រុសថ្លៃពន្លកនៅក្នុងក្រុង
ក្រែងមានរោគផងបៀតបិន្ទា    ឬមួយអ្នកជាសុខសាន្តទេ ។
២៧៧-ដ្បិទប្អូនឯនាយតែងគិតនឹក    អាល័យរឭកសព្វថ្ងៃខែ
បានទៅយល់មុខអ្នកឪម៉ែ    បានល្ហែសប្បាយទុក្ខរាល់គ្នា ។
២៧៨-ប៉ុន្តែខ្លួនប្អូនមានទុក្ខធំ    ដូចភ្នំរលំលើឱរា
ដ្បិតតែអ្នកម៉ែគាត់មោហា    លោភដោយទ្រព្យាពុំគិតស្លាប់ ។
២៧៩-គាត់ឱ្យដំណឹងទៅអរជូន    ឱ្យយកអាង្គួនមកផ្គួផ្គាប់
ផ្សំខ្ញុំរៀបការជាប្រញាប់    ឯប្អូនសូរស្លាប់ទៅក៏ជា ។
២៨០-បើអ្នកអាសូរប្អូនបណ្តូល    ឱ្យឡើងក្រាបទូលព្រះរាជា
សូមព្រះបន្ទូលទៅម្នីម្នា    កុំឱ្យរៀបការនោះទើបបាន ។
២៨១-ហើយស្រេចរេចដាក់ក្នុងថង់ស្លា    បារីមូរផ្លូង់អស់ពីប្រាណ
ពីព្រោះនាងទារចង់ឱ្យបាន    ប្តីមកយកនាងទៅស្រុកវិញ ។
២៨២-នាងប្រើអាមាសនិងអាហង្ស    ចូរអាយកថង់របស់អញ
ទៅជូនម៉ឺនឯកគូសម្លាញ់    ថាអញឱ្យយកមកជម្រាបជូន ។
២៨៣-អាទៅរូតរះទាំងថ្ងៃយប់    កុំអាឈរឈប់ឱ្យមាំមួន
កុំធ្វេសប្រហែសការលើខ្លួន    ដល់ថ្ងៃយប់ជូនកុំឱ្យខាន ។
២៨៤-អាមាសនិងអាហង្សបានថង់ប៉ាក់    ពីរនាក់ក្រវាត់គាតប្រុងប្រាណ

ហើយយកអង្គរច្រកទៃបាន    អាទាំងពីរប្រាណចរយាត្រា ។
២៨៥-កម្លាំងវាដើរលឿនលើសខ្យល់    មួយថ្ងៃបានដល់ជ្រោយចង្វា
ឆ្លងមកសំណាក់វត្តលង្កា    ព្រឹកឡើងសូមលាលោកចរចេញ ។
២៨៦-ពេលបាយបានដល់ស្រុកឱដុង្គ    អាមាសយកថង់នោះឯងមិញ
ជូនទៅម៉ឺនឯកស្រាយថង់ចេញ    ឃើញស្លាបារីពេញមានចិត្រអរ ។
២៨៧-ហើយឃើញសំនួរពីប្អូនស្រី    មើលដឹងសេចក្តីដូចត្រូវសរ
ឈឺឆៀបហាក់ហៀបដូចនឹងមរណ៍    ដាស់ម៉ឺនពេជ្រក្រោកឡើងទៅគាល់ ។
២៨៨-អធ្រាត្រស្ងាត់ច្រៀបដាស់ទំ    សន្មើមបំព្រាំស្តេចផ្ទំស្កល់
ម៉ឺនឯកម៉ឺនពេជ្រឡើងទៅគាល់    ពុំគិតពីភាល់ត្រង់ក្តីស្លាប់ ។
២៨៩-ម៉ឺនពេជ្រផ្លុំប៉ីម៉ឺនឯកច្រៀង    សូរស័ព្ទពីរោះរម្យចំណាប់
អស់អ្នករឭកឡើងប្រឹងស្តាប់    ម៉ឺនឯករាយរៀបទំនុកថា ។
២៩០-ស្រណោះខ្លួនធ្លាប់នៅជាខ្ញុំ    ធ្លាប់ផ្លុំប៉ីច្រៀងថ្វាយរាជា
ធ្លាប់គាល់ធ្លាប់ឃើញព្រះភក្ត្រា    ឥឡូវសមឃ្លាតឃ្លាទៅឆ្ងាយ ។
២៩១-ពីថ្ងៃនេះហើយនឹងគ្មានសុខ    តែទុក្ខលើសដើមថ្លើមស្ទើរធ្លាយ
នេះគឺកម្មព្រេងមកពីនាយ    នឹងថ្វាយបង្គំសូមក្រាបលា ។
២៩២-ស្តេចតើនចាកពីព្រះបន្ទំ    ស្តាប់សូរប៉ីផ្លុំទ្រង់សង្កា
ស្តេចបែរទៅបើកព្រះកៅរតា[233]    មានព្រះឱង្ការសួរឆាប់ខ្មី ។
២៩៣-ម៉ឺនឯកបង្គំក្រាបទូលថា    នាងទាវស្នេហាជាខ្ញុំស្រី
មានជាសំនួរក្នុងថង់ថ្មី    ឯក្នុងសេចក្តីកើតសៅហ្មង ។
២៩៤-អានថានាងទាវសូមសួរមក    ប្រុសថ្លៃពន្លកនៅក្នុងក្រុង
ក្រែងមានរោគាបៀតបៀនអង្គ    ឬមួយអ្នកបងសុខជាទេ ។
២៩៥-ប្អូននៅឯនាយតែងគិតនឹក    អាល័យរឭកសព្វថ្ងៃខែ
បានទៅយល់មុខអ្នកឪម៉ែ    ក៏សុខជាទេទាំងអស់គ្នា ។
២៩៦-ប៉ុន្តែខ្លួនប្អូនមានទុក្ខធំ    ដូចភ្នំរលំលើឱរា

233កវតា(ក្បួនរាជសព្ទ, *Traité de vocabulaire royal*, Royaume du Cambodge, 1942, p. 39.

ព្រោះតែអ្នកម៉ែគាត់មោហា លោភដោយទ្រព្យពុំតាមច្បាប់ ។
២៩៧-គាត់ឱ្យដំណើរទៅអរជូន ឱ្យយកអាងួនមករណ្ដាប់
ផ្សំប្អូនរាប់រៀបការជាប្រញាប់ តែប្អូនស៊ូស្លាប់ទៅក៏ជា ។
២៩៨-បើអ្នកអាសូរប្អូនបន្ទូល ឱ្យឡើងក្រាបទូលព្រះរាជា
សុំព្រះបន្ទូលឆាប់ម្ទីម្ទា ឃាត់កុំឱ្យការនោះទើបបាន ។
២៩៩-ស្ដេចស្ដាប់សំនួរនាងទាវហើយ ក្សិណក្សត្រត្រាណត្រើយបន្ទូលថ្កាន
ទាវទៅដើងមុខម្ដេចរាហ៊ាន លើកស្លាបំពានពុំខ្លាចស្លាប់ ។
៣០០-ព្រោះតែម្ដាយទាវនិងអរជូន រាយកអាងួនមកផ្គូផ្គាប់
មិនខ្លាចមុខអញពេញខុសច្បាប់ គួរកាប់ក្បាលដោតកុំប្រណី ។
៣០១-ហើយទ្រង់សរសេរព្រះឱង្ការ បោះព្រះសង្ការឱ្យឆាប់ខ្មី
ប្រទានឱ្យឯកស្រេចហើយនៃ ដាក់លើសិរសីបង្គំលា ។
៣០២-ឱ្យហៅអស់ពួកស៊ីផាយ ប្រញាប់ប្រញាយរៀបទូកក្ដារ
អ្នកខ្លះយកចែវយកច្រវា អង្ករម្លូស្លាឱ្យមានគ្រប់ ។
៣០៣-រួចស្រេចម៉ឺនឯកចុះនាវា ស្រាយពួរម្ទីម្ទាចេញទាំងយប់
ស្រូតរូតមិនបានឱ្យឈរឈប់ បីយប់បានដល់ខែត្រត្បូងឃ្មុំ ។
៣០៤-ចូលបៀតចាប់ចតនៅកំពង់ ហៅពាមមាត់ខ្នុងទូកចតជុំ
ដណ្ដាំបាយទឹកស៊ីរងុំ ស៊ីឆ្អែតប្រជុំគ្នាឡើងគោក ។
៣០៥-ឯកទៀងទួញថាឱស្ងួនភ្វារ បងមើលអស់គ្នាឥតទុក្ខសោក
កម្មអ្វីមកឱ្យបងស្កាំងស្កម គឺពៀរបងមកពីបូរាណ ។
៣០៦-ឡើងដល់ត្បូងឃ្មុំស្រុកជុំ ស្រុកនោះធារធំសម្បូរបាន
លេចរាលចូលព្រៃស្ងាត់ស្មសាន រសៀលទើបបានដល់ផ្ទះម្ដាយ ។
៣០៧-ក្សិណនោះឯម្ដាយបានយង់យល់ ម៉ឺនឯកមកដល់បានសប្បាយ
អស់ញាតិសន្ដាននៅជិតឆ្ងាយ រត់មកប្រញាយសាកសួរគ្នា ។
៣០៨-រីឯម៉ឺនឯកឡើងលើផ្ទះ លើកដៃសំពះឱនសិរសា
ជម្រាបសូមសួរអ្នកមាតា នាងទាវគេការថ្ងៃណាហើយ ។
៣០៩-កាលនោះម្ដាយឯកឆ្លើយតបថា ហៃកូនពុំងាមាសម្ដាយអើយ

គេនាំខាន់ស្លាព្រឹកនេះហើយ  កូនអើយគេហៅម្ដាយដែរ ។
៣១០-ប៉ុន្តែខ្លួនម្ដាយមិនចង់ទៅ  អញប្រើឪឯងគាត់ទៅហោង
ដោយផ្លូវក៏ឆ្ងាយក្រៃកន្លង  អញចាស់ឈឺខ្នងមិនចង់ទៅ ។
៣១១-ម៉ឺនឯកអង្វរទៅមាតា  អ្នកកុំយាត្រាឱ្យហ្មងសៅ
ផ្លូវឆ្ងាយហើយសោតសឹងតែក្ដៅ  ឱ្យខ្ញុំបាទទៅចងដៃទារ ។
៣១២-ឯម្ដាយបានឮពាក្យកូនឃាត់  ឆ្លើយថាតាមចិត្តអ្នកមាសថ្លៃ
ម៉ឺនឯកហៅពេជ្រឱ្យយកប៉ី  ព្រះបន្ទូលក្សត្រថ្លៃជាប់នឹងខ្លួន ។
៣១៣-នេះនឹងស្រដីឯឱកញ៉ា  អរជូនម្ទីម្ទរៀបការកូន
ជុំញាតិសន្ដានជួបបងប្អូន  រៀបសែងជញ្ជូនអស់មាន់ទា ។
៣១៤-អ្នកខ្លះសែងជ្រូកខ្លះសែងក្ដាន់  ជារយជាពាន់មកត្រៀបត្រា
សាច់គោក្របីត្រីញាំភ្លា  អ្នកខ្លះចេះសារដោយទឹកខ្មេះ ។
៣១៥-អ្នកខ្លះសែងល្មេចទាំងទន្សាយ  អណ្ដើកកន្ធាយមកច្រឡេះ
ហើយយកអន្ទង់ញាំទឹកខ្មេះ  បោចបេះបន្លែផ្សំនឹងបាយ ។
៣១៦-ជញ្ជូនវណ្ដាប់ស្រេចមកការ  ប្រដាប់ប្រដានំទាំងឡាយ
កន្ត្រក់ខ្ញៀនទៀនផ្លែអាយ  នំរ៉ែងអន្សាយនំបញ្ចុក ។
៣១៧-នំត្រៀបអន្សមនំគមលត  នំខ្ញីនំគ្នោតនំពងក្អុក
កន្សោមចាបស៊ីឆ្អាបមាននំក្រុក  នំជាលម្សៅបុកត្រចៀកពួង ។
៣១៨-នំក្រៀបនំថ្មនំរពៅ  នំចេកស៊ីទៅយ៉ាងនំកង
នំក្រួចបង់ខ្លាញ់ឆ្ងាញ់កន្លង  កូនដើរស្ទាបខ្នងថារុយទំ ។
៣១៩-វីឯនំចិនឈ្មោះការច័ន្ទ  ផុំក្លិនម្លើនៗនំអាបធំ
តាវគួយតែមួយដាក់បន្លំ  នំពាមូលត្ពុំកាឡោវជី ។
៣២០-ឯនំអន្សមតាម៉ាចាំង  គេដាក់ក្នុងឆាំងហៅនំអ៊ី
កៅច័ន្ទមីសួផ្អែមគ្រាន់ស៊ី  នំតាវគួយទីនិងនំជៅ ។
៣២១-ហើយមាននំយួនឱ្យគ្រប់យ៉ាង  បាញ់គ្រាងបាញ់ស៊ុងបាញ់ហូវក្វះ
បាញ់ស៊ុងបាញ់ហយបាញ់អ៊ិចតា  បាញ់បោរពីសាបាញ់អើកផង ។
៣២២-បន្លែស្រុកចិនទិញឱ្យគ្រប់  មីសួតាំងហុនផ្កាចេកហោង

បួចកាក់ឡៅហារគួយទារផង ប្លោកត្រីបង្កងឈ្លើងសមុទ្រ ។

៣២៣- បន្លែស្រស់យើងស្លក្តៅៗ ត្រឡាចរពៅឃ្លោកក្រញូក

ត្រសក់ទ្រើងខ្ទឹមភ្លើងត្រប់កំបុត មួយរយមុខសុទ្ធតែបន្លែ ។

៣២៤- ចុងភៅស្លស្រេចរៀបដាក់ថាស ជញ្ជូនរទាសដាក់បង្កែ

ហៅភ្ញៀវមកជុំហើយផឹកប៉ៃ ជជែកគ្នាអែលើគ្រឹហា ។

៣២៥- ហើយលេងភ្លេងភ្លាត់តូរ្យតន្ត្រី វាយស្គរផ្លុំប៉ីបង្អកស្រា

ស្រវឹងស្រែកច្រៀងធ្វើឡោរឡារ ការនេះណាចងដៃងួនទារ ។

៣២៦- អស់ញាតិសន្តានមកជួបជុំ ពីសារងុំសើចខ្ទាកខ្ទៀវ

ស្រវឹងប្រឹងស្រែក(ហ៊ោ)កញ្ជ្រៀវ ចងដៃងួនទារវាងផ្លែឈើ ។

៣២៧- ម៉ឺនឯកម៉ឺនព្រេជឡើងទៅដល់ គេហៅរចល់ឱ្យទៅលើ

ផឹកស៊ីសប្បាយពុំមានស្មើរ អាងជាបំរើស្តេចមេត្តា ។

៣២៨- ម៉ឺនឯកចងដៃប្រាក់ប្រាំតម្លឹង ឱ្យនាងទារដឹងក្នុងប្រាជ្ញា

នាងទារយល់ឯកគូស្នេហា ក្នុងទ្រូងអួលផ្សាស្មើរនឹងធ្លាយ ។

៣២៩- ពុំហ៊ាននឹងហាចេញស្រដី ដ្បិតខ្លួនជាស្រីគន់គិតកាយ

ហើយខ្លាចអរជូនអាពុកម្តាយ កាត់ចិត្រពុំស្តាយជីវិតស្លាប់ ។

៣៣០- នាងផាត់វាំងននចេញមកក្រៅ ហៅទៅម៉ឺនឯកប្រុសចំណាប់

អ្នកច្រៀងមួយមាត់ឱ្យប្អូនស្តាប់ អ្នកប្រុសចំណាប់ប្រាសគ្នាហើយ ។

៣៣១- ប្តូឯម៉ឺនឯកឃើញភរិយា ចេញមកដង(ស្រា)ដូច្នោះហើយ

ប្រឹងបែរឱ្យបៀតជិតបង្កើយ ពុំគិតខ្លាចឡើយផឹកលើដៃ ។

៣៣២- ពុំមានគិតខ្លាចមុខនរណា រួចហើយនាងវារចូលវិលវៃ

ឯកច្រៀងបញ្ជៀងឱ្យច្រើនក្រៃ ពុំខ្លាចសេចក្តីដែលមរណា ។

៣៣៣- គ្រានោះអរជូនបានស្តាប់ជាក់ ខឹងដូចគេញាក់អស់អង្គា

ហើយសួរថាវាមកពីណា ក៏ហានមកថាសង្សារឯង ។

៣៣៤- កំពុងគេរៀបការសួស្តី វាមកស្រដីលែងជាល្បែង

ស្រវឹងស្រាស្រែកច្រៀងក្តែងៗ អាដែងនេះពេញជាអ្នកកាច ។

៣៣៥- អើយអស់ទាហាននៅក្រៅរបង ចូលមកចាប់ចងអាកំណាច

នាំទៅសម្លាប់វាកុំខ្លាច កាប់វាឱ្យក្អែកត្មាតវាស៊ី ។
៣៣៦- អស់ទាំងបាវព្រាវវាបានស្តាប់ នាំគ្នាប្រញាប់ចាប់ញកញី
ខ្លះថងខ្លះធាក់ធ្លាក់ទៅដី ប្រុសស្រីផ្អើលឆោពកូនចៅ ។
៣៣៧- ហេតុតែកម្មឯកមកពីព្រេង រងេ្វងឱង្ការព្រះចមចៅ
លាក់ក្នុងចង្កេះពុំឱ្យទៅ ដោយសេចក្ដីក្ដៅភ្លេចវិញ្ញាណ ។
៣៣៨- ខំស្រែកច្រៀងហៅទៅទាវថា ហៃកែវស្នេហាមាសកល្យាណ
គេចងគេចាក់មុតសុសប្រាណ ម៉្លេះហើយស្រីគ្មានអាសូរបង ។
៣៣៩- ខំស្រែកច្រៀងទៀតថាទាវអើយ គេចាក់ត្រូវហើយកណ្ដាលខ្នង
ឈាមហូរដាបអាវប្រាំជាន់ផង ម៉្លេះហើយសមបងឃ្លាតប្អូនស្រី ។
៣៤០- ទាវអើយនាងនៅឯក្រោយបង កុំឱ្យមានហ្មងនឹងប្ដីសី
ចិត្របងកំពុងតែបេតី បងសូមលាស្រីទៅស្លាប់ហើយ ។
៣៤១- ឯខ្ញុំអាងួនវាកន្ត្រាក់ ឈាមហូរសស្រាក់ពុំក្រែងឡើយ
ដល់ពោធិ៍ទង្គុំព្រៃល្វេងល្វើយ ឯកថាវីយើយកុំអាលកាប់ ។
៣៤២- ឯងទៅយកពូកខ្នើយព្រៃព្រាំ របស់ដែលដៃទាវប្រដាប់
ឯខ្ញុំអាងួនរត់ឆាប់ៗ ទៅយកក្រាលស្រេចឱ្យឯកដេក ។
៣៤៣- ឯកឡើង(លើ)ពូកធ្មេចនេត្រា វាងាដាវលើកក៏សផ្លេក
ហើយកាប់ដាច់កស្លាប់ទៅទាំងដេក ចោលខ្មោចម៉ឺនឯកកណ្ដាលព្រៃ ។
៣៤៤- ឯអស់ទាហានវិលក្រឡាប់ មកប្រាប់អរជូនតាមសេចក្ដី
ថាយើងកាប់វាចោលហាលថ្ងៃ ហើយយើងវិលវៃមកម្ទីម្ទា ។
៣៤៥- វីឯនាងទាវឮដំណឹង បានដឹងជាប្ដីក្ស័យជន្មា
រន្ធត់ស្លុតស្លាំងគាំងកាយា គឺមោះធ្វើហាក់(ដូច)គួរក្សាន្ត ។
៣៤៦- ហើយស្ដីស្រាក់ស្រួលនឹងមេបា មិនឱ្យអាងួនវាដឹងដាន
ជេរថាអាប្រេតចៅតិរច្ឆាន វាហានថាខ្ញុំជាសង្សារ ។
៣៤៧- សមតែទៅកាត់អណ្ដាតចេញ ជេះធ្មេញ(វា)កុំឱ្យធ្លាប់ថា
ចៅងួនឃើញទាវខឹងដូច្នេះណា ពុំគិតសង្កាក្នុងហទ័យ ។
៣៤៨- លុះថ្ងៃទន់ទាបទៅទាវហៅមេនោ មកហើយនៃប្រាប់មេនោថា

អញលានាងទៅក្ស័យជន្មា    ហទ័យរង្វេងធ្វេសរាយមាយ ។
៣៤៩-មេនោព្ហើយយំថាទៅ    សង្ឃឹមអ្នកជាប្តីដូចម្តាយ
ឥឡូវអ្នកនឹងទៅស្ថានឆ្ងាយ    ក្រងាយទៅមុខមាននរណា ។
៣៥០-អ្នកស្លាប់ខ្ញុំក៏ទៅស្លាប់ផង    បើនៅនឹងរងតែទុក្ខា
ខ្ញុំទៅស្លាប់ផងជាមួយគ្នា    ទៅកើតជាតិណាព្រមទាំងប្តី ។
៣៥១-នាងនាំមេនោចេញទ្វារក្រោយ    លបដើរបណ្តោយកាត់ក្នុងព្រៃ
ឃើញក្មេងអ្នកស្រុកឃ្វាលក្របី    ស្រីថ្លៃហៅក្មេងមកផ្តាំថា ។
៣៥២-បងឱ្យចិញ្ចៀនមាសត្បូងមួយ    ប្អូនជួយធុរៈបងតិចរ៉ា
បើឯងទៅដល់ផ្ទះគេការ    ឯងច្រៀងឱ្យគ្នាមួយទំនុក ។
៣៥៣-ឱលោកចាស់ទុំលោកសប្បាយ    ផឹកស៊ីនិយាយគ្នាស្រណុក
ពុំដឹងជាទារដែលកើតទុក្ខ    ថ្ងៃក្រោយនឹងផុតអស់ទាំងគ្នា ។
៣៥៤-អាល័យតែផឹកស្រាស្រវឹង    ពុំដឹងជាខ្លួននឹងមរណា
ម៉ឺនឯកនាងទារមេនោណា    ស្លាប់គរជាមួយគ្នាកណ្តាលព្រៃ ។
៣៥៥-នាងផ្តាំក្មេងៗស្រេចហើយណា    ញ័រអស់កាយាចរឃ្លាឃ្លៃ[234]
ទឹកភ្នែកហូរល្វែងតែងរំពៃ    ឃើញនៃខ្មោចឯកឧបេក្ខា ។
៣៥៦-នាងឱបខ្មោចឯកហើយទួញយំ    ចុកឈាមដាលដំអន់អួលផ្សា
នាងស្រាយព្រះបន្ទូលពីក្រមា    ដាក់លើសិរសាអ្នកម៉ឺនឯក ។
៣៥៧-ប្អូនសុំលុងមួយខំឆ្លាក់ឆ្លៀត    ក្រែងរាចង្អៀតនឹងអ្នកពេក
សុំតែផ្នូរមួយកុំឱ្យបែក    អ្នកឯកម្តេចអ្នកមិនស្រដី ។
៣៥៨-ធ្លាប់នៅធ្លាប់នែបសុខសប្បាយ    និយាយលួងលោមរួមបេតី
ឥឡូវម្តេចឡើយអ្នកប្រុសថ្លៃ    អ្នកស្ងៀមមិនស្តីកាន់ប្អូនឡើយ ។
៣៥៩-នាងទៀងទួញគ្រប់ប្រការ    សព្វដោយស្នេហាពុំត្រាស្បើយ
ទាញយកកាំបិតស្លាមកហើយ    វិញ្ញាណល្វេងល្វើយអារកស្លាប់ ។
៣៦០-មេនោឃើញទារស្លាប់ចោះណា    យកកាំបិតស្លាមកផ្គូផ្គាប់

[234] En khm mod. ឃ្លាតឃ្លៃ.

ផ្អៀងផ្អែកប្រះដេកខាងឯកស្រាប់ ហើយអារកស្លាប់ជាមួយគ្នា ។
៣៦១-ប្រុងអស់ក្មេងដេញក្របី ទៅដល់ផ្ទះថ្មីកំពុងការ
ហើយវាស្រែកច្រៀងបញ្ជៀងថា តាមពាក្យប្ដេជ្ញានាងទារនៃ ។
៣៦២-ឯអស់ចាស់ទុំនៅលើផ្ទះ ឮក្មេងវាច្រៀងកើតសង្ស័យ
សួររកនាងទារស្រីវ័ន្តថ្លៃ រចល់ទីទៃទាំងអស់គ្នា ។
៣៦៣-ឱ្យរកសព្វល្វែងពុំយល់ឡើយ ពុំឃើញហើយឱ្យបសួរថា
មិនជឿជានាងទៅមរណា ខ្លះវាទៅប្រាប់លោកអរជូន ។
៣៦៤-ថាបាត់នាងទារពុំឃើញទេ មានតែលោកប្រើអ្នកម៉ឺនងួន
ឱ្យហៅសន្តានហៅបងប្អូន ឱ្យជូនទៅរកពោធិ៍ទង្គុំ ។
៣៦៥-ម៉ឺនងួនឮគេយកថាដូច្នោះ រំជួលក្នុងពោះទ្រហោយំ
ទ្រួញថាឱមាសមិត្រឧត្តម បងខំអស់ប្រាក់មិនគិតស្ដាយ ។
៣៦៦-នរណាបញ្ឆោតនាងស្រីពៅ យកទារសម្លាប់ខ្លួនអន្តរាយ
អាណិតតែចិត្រប្អូនឆោមឆាយ ថ្ងៃមិញនិយាយប្រាប់បងទេ ។
៣៦៧-ហើយដើរទៅដល់ពោធិ៍ទង្គុំ ឃើញខ្មោចបីជុំស្លាប់បង្ហេ
ឃើញទាំងឱង្ការនោះនូវដៃ ម៉ឺនងួនយកតែព្រះឱង្ការ ។
៣៦៨-មកឱ្យអរជូនបានឃើញហើយ ក្នុងចិត្រពុំស្បើយកើតសង្កា
កាលមុនម្ដេចឡើយវាមិនថា សមយើងវាល់គ្នានឹងកើតទុក្ខ ។
៣៦៩-ប្រុងសន្តាននៅឆ្ងាយជិត រួតរត់ប្រញាប់ទៅដោយស្រុក
ខ្លះយករបស់ទៅលាក់ទុក ពួនជ្រកក្នុងគុកក្នុងគុហា ។
៣៧០-នេះនឹងស្រដីឯម៉ឺនពេជ្រ ឃើញគេចាប់ឯកទៅប្រហារ
ម៉ឺនពេជ្រភិតភ័យរត់ម្នីម្នា ឆ្លងកាត់បឹងប្រាមកដល់មាត់ឃ្មុំ ។
៣៧១-ចុះទូកហើយចែវទាំងថ្ងៃយប់ នឿយហត់ល្ហិតល្ហៃដល់កំពង់
លួងឡើងទាំងយប់ងងិតសុង ចូលក្នុងវាំងរែងកំផែងឆ្ងាយ ។
៣៧២-ដើរម្នាក់ឯងកណ្ដែងស្ងាត់ បាត់ឯកក្នុងទ្រូងស្មើរនឹងធ្លាយ
ចូលដល់ដំណែលដែលច្រៀងថ្វាយ ឃើញតែអករំយាយដេកត្រៀបត្រា ។
៣៧៣-បាត់ឯម៉ឺនឯកពុំឃើញឡើយ កម្មអើយមករងតែងទុក្ខា

សែនក្តៅក្នុងមនោទោមនស្សា ស្រក់ទឹកនេត្រាហៀរហូរខ្វាយ ។
៣៧៤-ហើយទើបទាញយកប៉ីមកផ្លុំ ជាបទខ្នងភ្នំនឹងក្រោមនាយ
ដាស់ទំស្រងាត់ខ្យល់ផាត់ផាយ សន្សើមប្រស់ប្រាយដល់សេយ្យាសនា ។
៣៧៥-នាយយាមវាយគងចូលម៉ោងប្រាំ អស់អ្នកចំណាំភ្ញាក់រាល់គ្នា
រៀងខ្លួនរៀបក្លស់កម្រងផ្កា ថ្វាយមហាក្សត្រាប្រក្រតី ។
៣៧៦-ស្តេចឮសំឡេងប៉ីម៉ឺនពេជ្រ ពីរោះឮលេចក្នុងរាត្រី
ជ្រួតជ្រាបក្នុងដួងហទ័យ ព្រះចក្រីតើនចាកសន្និយា ។
៣៧៧-លប់លាងព្រះភ័ក្រ្តថ្លៃស្រឡះ មានព្រះបន្ទូលសួរទៅថា
ឮតែប៉ីពេជ្រឯកទៅណា បានជាពុំឮអង្គីក្តី ។
៣៧៨-ម៉ឺនពេជ្រក្រួញក្រាបបង្គំថា សូមទ្រង់មេត្តាប្រោសប្រណី
ឱកញ៉ាអរជូនចិត្រធំក្រៃ សម្លាប់ឯកក្ស័យពុំមេត្តា ។
៣៧៩-ម៉ឺនឯកទើបឡើង(ដល់)លើផ្ទះ ពុំទាន់យកព្រះរាជឱង្ការ
ទទួលនាងទារចេញដងស្រា ហៅឯកស្នេហាឱ្យច្រៀងខ្មី ។
៣៨០-ម៉ឺនឯកស្រែកច្រៀងដូចសព្វដង អរជូនឱ្យចងឯកញ្ញកញ្ញី
ពុំដឹងជាមានទោសពីអ្វី ទូលបង្គំភិតភ័យរត់ប្រញាប់ ។
៣៨១-កាត់ស្រុកតត្រុកតែក្នុងព្រៃ ប្រទះដំរីភ័យស្ទើរស្លាប់
ឆ្លងបឹងឆ្លងស្ទឹងឱ្យខាងឆាប់ ក្រោយនោះវាកាប់ម៉ឺនឯកហើយ ។
៣៨២-ម៉ឺនពេជ្រក្រាបទូលសព្វសេចក្តី យកប៉ីមកផ្លុំសូរល្វេងល្វើយ
ឯចិត្រនឹកឯកពុំមានស្បើយ ឈាមចុកកហើយដាច់ខ្យល់ស្លាប់ ។
៣៨៣-ស្តេចយល់ម៉ឺនពេជ្រក្ស័យជន្មា ក្នុងព្រះទយា[235]ខ្វាល់ញាំញាប់
តន្រ្តំព្រះបាទស្រែកសន្ធាប់ បង្គាប់ឱ្យហៅយមរាជា ។
៣៨៤-តម្រួតក្រាបលារាចេញទៅ ដល់ហើយស្រែកហៅពីក្រៅទ្វារ
យមរាជឮហើយភ័យតក្កមា រូតរត់ម្នីម្នាមកឆាប់ខ្មី ។
៣៨៥-ស្តេចមានបន្ទូលទាំងអមោក្ស នៃលោកយមរាជគួរទេរី

---

[235]ព្រះហឫទយា

ឱកញ៉ាអរជូនចិត្រធំក្រៃ
កាប់ឯកអញក្ស័យឥតជំនុំ ។
៣៨៦-ទោះបើទោសខុសម្តេចម្តា
ឱ្យពិចារណាដោយគួរសម
ដឹងជាម៉ឺនឯករាជាខ្ញុំ
ទុកជាទោសធំកុំអាលកាប់ ។
៣៨៧-មានតែធ្វើសំបុត្រមកក្រាបទូល
ចូលមកនោះទើបត្រូវនឹងច្បាប់
នេះរាចិត្រធំពុំខ្លាចស្លាប់
គួរកាប់ក្បាលដោតកុំប្រណី ។
៣៨៨-ចូលទៅហៅអស់ទាំងទាហាន
ឱ្យមានគ្រឿងសឹកឱ្យគ្រប់ដៃ
យកទាំងរាជតេជៈខាងដំរី
នគរបាលនៃឱ្យឆាប់ៗ ។
៣៨៩-បើរាតដៃកាប់ឱ្យល្អិត
ពុំមានអាណិតឱ្យពលចាប់
ដាក់យ្នាងដាក់ត្រោកខាងឱ្យជាប់
ជូនមកប្រញាប់ឱ្យទាន់ចិត្រ ។
៣៩០-ទាំងញាតិសន្តាននឹងអរជូន
បងប្អូនកូនចៅនៅឆ្ងាយជិត
រើរឹបយកទ្រព្យកុំឱ្យគិត
ដុតផ្ទះលំអិតកុំឱ្យសល់ ។
៣៩១-រីឯខ្មោចពេជ្រស្តេចផ្តាំថា
ត្រូវពួកស្នំយកទៅតម្កល់
ទុកធ្វើជាមួយសោះររល់
សាងផលជំពោះសោះព្រួយប្រាណ ។
៣៩២-យមរាជក្រាបលារាចេញថ្វាត់
ឱ្យចាត់ពលរេហ៍គ្រឿងទាហាន
ស៊ីផាយរៀបទូកប្រៀបប្រុងប្រាណ
ស្រេចបានពេលាចរចេញទៅ ។
៣៩៣-តឿនគ្នាឱ្យចែវទាំងថ្ងៃយប់
មិនឱ្យឈរឈប់ប្រឹងសំដៅ
ផ្លាស់គ្នាស្រូតរូតពុំខាននៅ
ដល់ទៅមាត់ឃ្មុំឡើងរៀបរាយ ។
៣៩៤-តាំងជាក្បួនទ័ពតាមតម្រា
លើកដោយមាគ៌ាផ្លូវសោតឆ្ងាយ
ប្រយត្នប្រុងប្រៀបទៅអាយ
ដល់ហើយក៏រាយទ័ពព័ទ្ធផ្ទះ ។
៣៩៥-ចូលចងអរជូនទាំងភរិយា
ហើយចាត់ឱកញ៉ារាជតេជះ
រឹបរើរបស់ទ្រព្យក្នុងផ្ទះ
កុំឱ្យលើសខ្វះតាមចំនួន ។
៣៩៦-កត់ទាំងរទេះសេះដំរី
ខ្ញុំប្រុសខ្ញុំស្រីខាងអរជូន
ចំណែកទ្រព្យខាងប្រពន្ធកូន
ឱ្យសែងជញ្ជូនទៅដាក់ទូក ។
៣៩៧-ហើយចាប់សន្តាននៅជិតឆ្ងាយ
ពុំត្រាអាណិតដាក់យ្នាងត្រោក
ញាតិខាងម្តាយទារឱ្យនាំមក
ចាត់យកនាំទៅដាក់ទូកចរចេញខ្ជី ។
៣៩៨-ហើយចាត់ឱកញ៉ាស្រីនគរបាល
ឱ្យខានធ្វើការដាក់ខ្មោចបី

ធ្វើរោងដំកល់សពនោះនៃ ភ្លេងតូរ្យតន្ត្រីចាំរក្សា ។
៣៩៩-ហើយឱ្យនិមន្តអស់ទាំងលោកសង្ឃ មកគង់សូត្រធម្មព្រះភារនា
ផ្លាស់ប្តូរដោយពេលរាល់វេលា ធ្វើតាមតម្រាឱ្យមាំមួន ។
៤០០-នេះនឹងស្រដីឯឧកញ៉ា យមរាជសេនានាំអរជូន
មកដល់កំពង់ហែតាមក្បួន អ្នកផងជញ្ជូនទំនិញទុក ។
៤០១-ចងនាំអរជូនបណ្តើរទៅ ដល់រោងសម្រាប់ដែលដាក់គុក
បញ្ចូលខ្នោះរយវាយរនុក នាយគុកថែទាំចាំរក្សា ។
៤០២-ឧកញ៉ាយមរាជឡើងក្រាបទូល ព្រះចមកំពូល(អ)ធិរាជា
បាននាំអរជូនមកហើយណា គ្រប់អស់អាជ្ញាត្រាស់បង្គាប់ ។
៤០៣-ស្តេចមានបន្ទូលត្រាស់ទៅថា យកវាចេញទៅឱ្យឆាប់ៗ
កុំឱ្យប្រណីធ្វើតាមច្បាប់ សោះក្រោយវាធ្លាប់ល្មើសរាជការ ។
៤០៤-ល្មមកាប់ស្មោរដោតតាមទោសទៅ យមរាជឮនូវព្រះឱង្ការ
ចេញមកបង្គាប់អស់យោធា ពេជ្ឈឃាដ(?)សេនានាំចេញទៅ ។
៤០៥-ឱ្យចងចំណងប្រាំប្រការ បណ្តើរដោយផ្សារអាក្រោសហៅ
ហើយបាចជ័រចុងពីក្រោយទៅ ឮនូវស្រែកអូយដួលផ្កាប់ផ្សារ ។
៤០៦-បញ្ចិះរទេះបោះដែកគោល ឱ្យបរបំបោលទៅតាមធ្លា
បីជុំឱ្យដាក់ចុះសិនវ៉ា ទាហានរាល់គ្នាកាប់ដាច់(ក)[236] ។
៤០៧-ឱ្យជីកដីកប់ត្រឹមគល់ក ឱ្យបររនាស់ដែកសម្រាប់
ដំរីរោងបរជាន់បំបេច ល្អិតខ្ទេចជាផង់ជាធូលី ។
៤០៨-ណាសល់បញ្ចូលជាអ្នកងារ សម្រាប់រាជការក្នុងផែនដី
ឱ្យគ្នាអាចត្បាញច្រៃងល្អី ចង្កឹះរែកដំបុតត្រីនាំមកថ្វាយ ។
៤០៩-ស្រេចហើយយមរាជឡើងក្រាបទូល ព្រះមកុដឥស្សរក្សត្រពណ្ណរាយ
ពុំចេរតែប្រោសយើងទាំងឡាយ អរជូនអន្តរាយរួចហើយណា ។
៤១០-ទាំងកូនប្រពន្ធសាច់សន្តាន ប្រមាណបួនរយក្ស័យជន្មា
នៅខានប្រាំរយសល់ទុកជា អ្នកងារអង្គរក្សប្រើការទៅ ។

[236]Cf. Ms. P. camb. 32.

៤១១- ញាតិខាងម្ដាយ ទារហុកសិបប្លាយ ដាក់ជាឃ្លាំងបាយ បំរើចៅ
ចេញរេនចូលរេនដោយវដ្ដរ រៀងទៅរាល់រាជ្យជាធម្មតា ។

៤១២- ទើបស្ដេចបង្គាប់អស់មន្ត្រី ធ្វើមេរុពាលៃឱ្យអស្ចារ្យ
នឹងបូជាសពទារឯកស្នេហា និងពេជ្រណាមេនោផង ។

៤១៣- បន្ទូលស្រេចហើយព្រះចក្រី ចូលក្នុងទែនទីដូចសព្វដង
រីឯអស់មុខមន្ត្រីផង ចាត់គ្នាអឹងកងតាមមុខងារ ។

៤១៤- ធ្វើមេរុមណ្ឌបស្រេចពុំលង់ ទើបក្រាបទូលអង្គចក្រីក្សត្រា
បូពិត្រសូមទ្រង់ព្រះមេត្តា មេរុមណ្ឌបរចនាស្រេចហើយនៃ ។

៤១៥- ទើបស្ដេចបែរបើកបន្ទូលថ្កាន ឧកញ៉ានគរបាលឯងឆាប់រៃ
នាំខ្មោចឯកទារមេនោនៃ ចូលមកក្រុងក្រៃឱ្យទាន់ការ ។

៤១៦- ឧកញ៉ានគរបាលបានស្ដាប់ហើយ ពិតពុំយូរឡើយរួសម្ទីម្ទា
ទើបរៀបចាត់ចែងអស់ទូកក្ដារ ចេញទៅម្ទីម្ទាជាប្រញាប់ ។

៤១៧- ដល់យកខ្មោចទាំងបីដាក់ទូក ស្រូតរូតនាំចូ(ល)តាមបង្គាប់
លើកដំកល់លើមេរុស្រេចស្រាប់ ផ្គូផ្គាប់ទាំងខ្មោចពេជ្រផងណា ។

៤១៨- ហើយមានទាំងភ្លេងតូរ្យតន្ត្រី របាំមហោរីច្រើនត្រៀបត្រា
សប្បាយផ្អើលផ្អូកក្នុងភារា រាស្ត្រផងមកមើលមីរអឹងកង ។

៤១៩- ហើយស្រេចនិមន្តអស់ព្រះសង្ឃ សូត្រព្រះធម្មបង្សុកូលតាមទំនង
ចេញចាយព្រះរាជទ្រព្យច្រើនកន្លង លុះបានវិលងសតទិវា ។

៤២០- ស្រេចហើយឱ្យបូជាព្រះភ្លើង ឆេះឡើងសុសសពប្អូនអង្គា
រើសធាតុពុំលង់រួចម្ទីម្ទា សង្គាយនាហើយឆ្លងបុណ្យស្រេច ៕

ចប់បរិបូណ៌តែប៉ុណ្ណោះឯង ។

ចារចប់នៅថ្ងៃសៅរ៍ ១៣ កើតខែអស្សុជ ចុល្លសក្ករាជ ១២៦៦ ឆ្នាំជូតទោស័ក